អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងឡូតូសត្វឆ្នាំទាំង១២**

**បុរេគណិត** បរិមាណ និងចំនួន (ស្គាល់ យល់លេខតាង រាប់ចំនួន និងគណនាលេខសាមញ្ញ។

**ភាសាខ្មែរ** ប្រើពាក្យសំដីកាយវិការនិងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (និមិត្តសញ្ញាតំណាងឱ្យសត្វនិង វត្ថុនានា)។
ការស្គាល់តួរអក្សរ (ការប្រើញាណរបស់ខ្លួនដើម្បីអភិវឌ្ឍបំណិនសមត្ថភាពទាំង៦)។ (ការយល់ដឹងអំពីភាពខុសគ្នានៃសូរសម្លេង)។

**គោលបំណង** ៖

**(បុរេគណិត)** ប្រាប់បានពីចមនួនលេខ និងយល់ន័យពី១ដល់១០តាមលំដាប់លំដោយ ឬលើពីនេះ។

**(ភាសាខ្មែរ)** ប្រាប់ពីឈ្មោះសត្វតាមរយៈការធ្វើចលនាកាយវិការគ្រាប់តាមនិមិត្តសញ្ញា។
ប្រាប់ឈ្មោះសត្វ វត្ថុផ្សេងៗដោយស្តាប់សំឡេង ឬ សង្កេតកាយវិការ។
ស្តាប់ និងបែងចែកសូរសម្លេងដូចជា សូរសម្លេងសត្វ សម្លេងមនុស្ស និងដឹងពីប្រភពសម្លេង

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតុងឡូតូ (សខ្មៅ, ពណ៌)
រៀបចំឈ្មោះសត្វទាំង១២ ហើយដាក់ក្នុងកាបូប ឬប្រអប់ និងវត្ថុដែលអាចប្រើសម្រាប់រាប់ចំនួនបានចំនួន៦ប្រភេទ។វត្ថុទាំងនោះមានដូចជា៖ គម្របដប ដុំថ្ម ឬជាដុំក្រដាស និងមានជាវត្ថុដែលរាប់ចំនួនបាន។ វាសម្រាប់បង្ហាញពួកគេថាតើពណ៌ណាដែលត្រូវបានស្រែកហៅ។

**ការរៀបចំ** ៖ បោះពុម្ព និងអ៊ុតកាតឱ្យបានស្អាត ទុកសម្រាប់ចែកឱ្យក្មេងៗ
ឈ្មោះសត្វទាំង១២ដាក់នៅក្នុងកាបូប ឬប្រអប់អ្វីមួយ
និងវត្ថុដែលអាចរាប់លេខបានមួយចំនួនដែរ

**សេចក្តីណែនាំ**

១. អ្នកគ្រូលោកគ្រូឱ្យក្មេងៗទាំងអស់និយាយពីឈ្មោះសត្វឆ្នាំទាំង១២និង បន្ទាប់មកអ្នកគ្រូលោកគ្រូសរសេរឈ្មោះសត្វនៅលើក្តារខៀនដែរ

២. បង្ហាញកាតុងឡូតូ ហើយសួរក្មេងៗថា តើក្នុងកាតុងឡូតូនេះជាសត្វអ្វី?

៣. ពន្យល់ពីរបៀបលេងល្បែងឡូតូសត្វឆ្នាំទាំង១២ដល់ក្មេងៗ

- ចែកក្មេងៗជាក្រុមតាមចំនួនជាក់ស្តែង។
- ត្រូវចែកកាតុងឡូតូល្បែងសត្វឆ្នាំទាំង១២តាមក្រុមនីមួយៗមួយឈុត និងដុំតូចៗ ឬគំរបដបក៏បានចំនួន ៦ដុំដូចគ្នា។
- ជ្រើសរើសក្មេងម្នាក់ជាអ្នកក្រឡុករូបសត្វឆ្នាំទាំង១២ចាប់យកកាតមួយសន្លឹកបន្ទាប់ មកហៅឈ្មោះសត្វនោះឱ្យលឺៗ។
- បើក្មេងៗណាមានសត្វដូចដែលគេហៅឈ្មោះនោះនៅក្នុងកាតុងឡូតូល្បែងរូបសត្វឆ្នាំ ទាំង១២ ក្មេងនោះត្រូវដាក់ដុំតូចៗ ឬគំរបដបសម្គាល់នោះនៅលើវា ។
- បន្ទាប់មកក្មេងចាប់ផ្តើមហៅឈ្មោះម្តងទៀត និងធ្វើដូចខាងលើដដែលរហូត។
- ក្មេងណាដែលបានបំពេញលើកាតុងល្បែងឡូតូរូបសត្វឆ្នាំទាំង១២នោះពេញមុននឹង ក្លាយជាអ្នកឈ្នះតែម្តង។
- បន្ទាប់មកអ្នកអាចលេងបន្តរកឈ្នះ ២ ឬ ៣ នាក់បន្តទៀតក៏បាន ។